**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ :..៧៥...សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតលេខាធិការដ្ឋានគណៈកម្មាធិការជាតដឹកនាំបញ្ហាការប្រយុទ្ធ និងទប់ស្កាត់អំពើភេរវកម្ម

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញសេចក្តីសំរេចរបស់រាជរដ្ឋាភិបាលលេខ ៨០ សសរ ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៤ ស្តីពីការបង្កើតគណៈកម្មាធិការជាតិ ដឹកនាំ បញ្ហាការប្រយុទ្ធប្រឆាំង និងទប់ស្កាត់អំពើភេរវកម្ម
- តាមសំណើររបស់ប្រធានគណៈកម្មាធិការជាតិ ដឹកនាំ បញ្ហាការប្រយុទ្ធប្រឆាំង និងទប់ស្កាត់អំពើភេរវកម្ម
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ ១:** បង្កើត លេខាធិការដ្ឋាន គណៈកម្មាធិការជាតិដឹកនាំបញ្ហាការប្រយុទ្ធប្រឆាំង និងទប់ស្កាត់អំពើភេរវកម្ម ហៅកាត់ លេខាធិការដ្ឋានគណៈកម្មាធិការជាតិប្រឆាំងភេរវកម្ម និងមានអក្សរកាត់ លេខាធិការដ្ឋាន គជបភ ។

**ប្រការ ២:** លេខាធិការដ្ឋាន គជបភ ជួយការងារប្រធាន គជបភ និង គជបភ អំពីការងារទាំងឡាយសំដៅបង្កើនប្រសិទ្ធភាពការប្រយុទ្ធប្រឆាំង និងទប់ស្កាត់អំពើភេរវកម្មដែលរួមមាន ៖

-កសាង ត្រួតពិនិត្យការអនុវត្តន៍ និងកែសំរួលយុទ្ធសាស្ត្រជាតិនៃការប្រយុទ្ធប្រឆាំងនិងទប់ស្កាត់ភេរវកម្ម

-ប្រមូល និងសរុបពត៌មានចារកម្មពីគ្រប់ស្ថាប័ន និងពត៌មានផ្សេងៗ - វិភាគវាយតំលៃ និងស្នើសុំវិធានការ

-ស្រាវជ្រាវអំពើភេរវកម្ម (ប្រមូលឯកសារ និងពត៌មាន - ចងក្រងឯកសារ និងពត៌មាន រាប់ទាំងឯកសារពត៌មានដែលបានពីបរទេសផង - សួរចម្លើយឈ្លេចយកពត៌មានបន្ថែមទៀតពីមុខសញ្ញា ក្នុង និងក្រៅប្រទេស)

-សិក្សារកចំណុចខ្សោយដែលត្រូវបំពេញ និងអ្វីដែលភេរវករអាចធ្វើបានដោយយើងនឹកគិតមិនដល់

-សិក្សាពង្រឹងសមត្ថភាព និងជំនាញក្នុងការប្រយុទ្ធប្រឆាំង និងទប់ស្កាត់ភេរវកម្ម

-បណ្តុះបណ្តាលជំនាញនានា និងបំពាក់បំប៉ន វិធីសាស្ត្រ ការប្រយុទ្ធប្រឆាំង និងទប់ស្កាត់អំពើភេរវកម្ម

-រៀបចំផែនការការពារគោលដៅ (ការពារហេដ្ឋារចនាសម្ព័ន្ធ)- ផែនការសង្គ្រោះ - និងផែនការឃោសនាអប់រំមហាជន - ដឹកនាំការផ្សព្វផ្សាយពត៌មានពេលមានគ្រោះ និងវិបត្តិកើតឡើង

-ជួយរៀបចំកម្លាំងពិសេស កម្លាំងអន្តរាគមន៍ និងកម្លាំងសង្គ្រោះបន្ទាន់ និងបណ្តាញ (ដូចជាបណ្តាញសង្គ្រោះបឋមជាមួយកាកបាទក្រហម) និងការងារជំនាញគាំទ្រនានាផ្សេងទៀត ដូចជាការងារកោសលវិច័យ - ការងារវិភាគគ្រឿងផ្ទុះ - ជាតិគីមី - ជីវសាស្ត្រ - វិទ្យុសកម្ម - នុយក្លេអ៊ែរ - និងមូលដ្ឋានបច្ចេកទេសសំងាត់ឬចំហរនានា

-កសាងធនាគារពត៌មានដោយប្រព័ន្ធកុំព្យូទ័រ និងកសាងមូលដ្ឋានបច្ចេកទេសកុំព្យូទ័រតភ្ជាប់ពត៌មាន ឯកសារ ពីច្រកទ្វារអន្តរជាតិ - ពីស្ថាប័ននានា មកលេខាធិការដ្ឋាន គជបភ

-សិក្សាទិដ្ឋភាពច្បាប់ - អនុសញ្ញា និងសន្ធិសញ្ញាអន្តរជាតិពាក់ព័ន្ធអំពើភេរវកម្ម និងធ្វើរបាយការណ៍នូវការអនុវត្តន៍ អនុសញ្ញា និងសន្ធិសញ្ញាអន្តរជាតិទាំងនោះ ជូនអង្គការសហប្រជាជាតិតាមពេលកំណត់

-ទំនាក់ទំនង និងសហការជាមួយប្រទេសនានាជាទ្វេភាគី និងពហុភាគី ផ្លាស់ប្តូរពត៌មាននិងការវិភាគព្រមទាំងបទពិសោធន៍ និងសំរបសំរួលប្រតិបត្តិការរួមទៅវិញទៅមក

-បំពេញការងារមួយចំនួនទៀត ដែលប្រធាន គជបភ និង គជបភ ប្រគល់ឱ្យ

**ប្រការ ៣:** លេខាធិការដ្ឋាន គជបភ ធ្វើសេចក្តីណែនាំលំអិតអំពីរបៀបរបប និងដំណើរការនៃការងារនិមួយៗខាងលើនេះថែមទៀត ដោយមានការពិនិត្យ និងបានការយល់ព្រមពីប្រធាន គជបភ ជាមុនសិន ។

**ប្រការ ៤:** សមាសភាពលេខាធិការដ្ឋាន គជបភ ៖

១- ឯកឧត្តម **ឯម សំអាន** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ - សមាជិក គជបភ ............................ ប្រធាន
(ទទួលបន្ទុករួម និងទទួលផ្ទាល់ទំនាក់ទំនងសំរបសំរួលការងារស្ថាប័នស៊ីវិល និងឯកជន)

២- ឯកឧត្តម **ហុក ឡង់ឌី** អគ្គស្នងការនគរបាលជាតិ - សមាជិក គជបភ ............................អនុប្រធាន
(ទទួលបន្ទុករួមលើរាល់កិច្ចការពារហេដ្ឋារចនាសម្ព័ន្ធ)

២- ឯកឧត្តម **ខឹម យ៉ិនឡេង** ទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី - សមាជិក គជបភ ................អនុប្រធាន
(ទទួលបន្ទុកពត៌មាន ស្រាវជ្រាវ បណ្តុះបណ្តាល សំភារៈ បច្ចេកទេស ទំនាក់ទំនង និងសហប្រតិបត្តិការជាតិ អន្តរជាតិ ទ្វេភាគី និងពហុភាគី)

៣- ឯកឧត្តម **មល់ រឿប** ទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី - នាយរងសេនាធិការចំរុះ និងជានាយកស្រាវជ្រាវចារកិច្ចអគ្គញ្ញាការដ្ឋានកងយោធពលខេមរភូមិន្ទ ..................................................អនុប្រធាន
(ទទួលបន្ទុកសំរបសំរួលទំនាក់ទំនងការងារយោធា)

៤- ឯកឧត្តម យូ ស៊ុនឡុង ទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី - អគ្គស្នងការរងនគរបាលជាតិ ......អនុប្រធាន

៥-ឧត្តមសេនីយ៍ឯក សៅ សុខា មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស ........................អនុប្រធាន

៦- ឯកឧត្តម ញៀម សុខារ័ត្ន ..............................................................អនុប្រធានប្រចាំការ

៧- ឧត្តមសេនីយ៍ឯក ស្វ ផន អគ្គស្នងការរងនគរបាលជាតិ ........................................សមាជិក

៨- ឧត្តមសេនីយ៍ឯក នេត្រ សាវឿន អគ្គស្នងការរងនគរបាលជាតិ ..................................សមាជិក

៩- ឧត្តមសេនីយ៍ឯក សុខ ផល អគ្គស្នងការរងនគរបាលជាតិ ........................................សមាជិក

១០- ឧត្តមសេនីយ៍ឯក ជា សារ៉ន មេបញ្ជាការរង និងជានាយសេនាធិការកងទ័ពជើងគោក ...........សមាជិក

១១- ឧត្តមសេនីយ៍ឯក ហ៊ីង ប៊ុនហៀង នាយករងខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី .................សមាជិក

១២- ឧត្តមសេនីយ៍ទោ ព្រហ្ម ឌិន មេបញ្ជាការយោធភូមិភាគពិសេស .................................សមាជិក

១៣- ឧត្តមសេនីយ៍ទោ កែវ សាម្ភួន មេបញ្ជាការយោធភូមិភាគទី ៣......................................សមាជិក

១៤- ឧត្តមសេនីយ៍ទោ ជា ម៉ន មេបញ្ជាការយោធភូមិភាគទី ៤..........................................សមាជិក

១៥- ឯកឧត្តម ហេង ពៅ ទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី និងជាស្នងការនគរបាលក្រុងភ្នំពេញ......សមាជិក

១៦- ឧត្តមសេនីយ៍ទោ ម៉ៅ សុផាន់ មេបញ្ជាការកងពលតូចលេខ ៧០ ......................................សមាជិក

១៧- ឧត្តមសេនីយ៍ត្រី ចាប ភក្តី មេបញ្ជាការកងពលតូចទ័ពពិសេសឆ័ត្រយោង ៩១១ ..................សមាជិក

១៨-តំណាងក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ - ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ - ធនាគារជាតិនៃកម្ពុជា - ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ - ក្រសួងយុត្តិធម៌ - ក្រសួងសាធារណការនិងដឹកជញ្ជូន - ក្រសួងពាណិជ្ជកម្ម - ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ - ក្រសួងសុខាភិបាល - ក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់ - រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល - គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា - គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ - អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន..........................................................................សមាជិក

**ប្រការ ៥:** លេខាធិការដ្ឋានរៀបចំបញ្ជីឈ្មោះជាក់ស្តែងឱ្យតំណាងក្រសួង ស្ថាប័ន ដោយស្នើសុំឱ្យរដ្ឋមន្ត្រី ឬប្រធានស្ថាប័នចាត់ឈ្មោះអ្នកមានសមត្ថកិច្ចមកឱ្យខ្លួន ហើយរៀបចំទាំងតំណាងស្ថាប័នដែលពាក់ព័ន្ធផ្សេងទៀតចូលមកក្នុងក្រុមគាំទ្រការងារ ដើម្បីបំរើឱ្យការធ្វើសៀវភៅផែនការការពារហេដ្ឋារចនាសម្ព័ន្ធ និងការងារវិភាគ ការងារប្រមូលពត៌មាន និងការងារជំនាញផ្សេងៗទៀតដែលចាំបាច់ ។ បញ្ជីឈ្មោះក្រុមគាំទ្រការងារនេះ ត្រូវដាក់ជូនប្រធាន គជបក ពិនិត្យ និងសំរេច ។

**ប្រការ ៦:** ក្នុងការរៀបចំធ្វើសៀវភៅផែនការតាមគោលដៅដើម្បីការពារហេដ្ឋារចនាសម្ព័ន្ធត្រូវបានចែកចេញជា ៣ ក្រុម:

១-ក្រុមការពារហេដ្ឋារចនាសម្ព័ន្ធទី ១ ហៅកាត់ហេដ្ឋា ១ ប្រគល់ជូនឯកឧត្តម សុខ ផល អគ្គស្នងការរងនគរបាលជាតិ ជាប្រធានក្រុមហេដ្ឋា ១ ដឹកនាំការងាររៀបចំសៀវភៅផែនការការពារសំរាប់គោលដៅ ៖

-អគ្គិសនី

-រដ្ឋាករទឹក



W

-ផ្លូវជាតិ

-ផ្លូវដែក

-អគាររដ្ឋ

-អគារឯកជន

២-ក្រុមការពារហេដ្ឋារចនាសម្ព័ន្ធទី ២ ហៅកាត់ហេដ្ឋា ២ ប្រគល់ជូនឯកឧត្តម **ឃុ ស៊ុនឡុង** ទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី និងជាអគ្គស្នងការរងនគរបាលជាតិ ជាប្រធានក្រុមហេដ្ឋា ២ ដឹកនាំការងាររៀបចំសៀវភៅផែនការសំរាប់គោលដៅ ៖

-ព្រលានយន្តហោះ

-កំពង់ផែ

-នាវាចរ (សមុទ្រ និងទន្លេ)

-ពិធីបុណ្យ-អង្គប្រជុំជាតិ-អន្តរជាតិ-គណៈប្រតិភូ

-ស្ថានទូត-កុងសុល-និវេសនដ្ឋានឯកអគ្គរដ្ឋទូត

-សាលាអន្តរជាតិ (ដែលមានកូនសិស្សបរទេសសិក្សា)

៣-ក្រុមការពារហេដ្ឋារចនាសម្ព័ន្ធទី ៣ ហៅកាត់ហេដ្ឋា ៣ ប្រគល់ភារកិច្ចជូនឯកឧត្តម **នេត្រ សាវឿន** ជាប្រធានក្រុមហេដ្ឋា ៣ ដឹកនាំការងារសិក្សាទិដ្ឋភាពច្បាប់ - អនុសញ្ញា និងសន្ធិសញ្ញាអន្តរជាតិពាក់ព័ន្ធអំពើភេរវកម្មនិងធ្វើរបាយការណ៍នូវការអនុវត្តន៍អនុសញ្ញានិងសន្ធិសញ្ញាអន្តរជាតិទាំងនោះជូនអង្គការសហប្រជាជាតិតាមពេលកំណត់និងទទួលការងាររៀបចំសៀវភៅផែនការ សំរាប់ ៖

-ការប្រឆាំងការលាងលុយកខ្វក់

-ការប្រឆាំងការធ្វើលិខិត ឯកសារក្លែងក្លាយ ការជួញដូរមនុស្ស

-ការប្រឆាំងបទឧក្រិដ្ឋផ្សេងៗទៀត រាប់ទាំងគ្រឿងញៀន

-គីមី ជីវសាស្ត្រ វិទ្យុសកម្ម នុយក្លេអ៊ែរ CBRN និងផែនការអន្តរាគមន៍សង្គ្រោះ រាប់ទាំងផែនការអន្តរាគមន៍សង្គ្រោះក្នុងករណី គីមី ជីវសាស្ត្រ វិទ្យុសកម្ម នុយក្លេអ៊ែរ ទៀតផង

**ប្រការ ៧:** ក្រុមវិភាគ និងចារកម្មប្រឆាំងភេរវកម្ម ត្រូវបានប្រគល់ភារកិច្ចជូនឯកឧត្តម **ខឹម យ៉ិនឡៀង** ទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី - សមាជិក គជបភ ជាប្រធានក្រុមវិភាគ និងចារកម្មប្រឆាំងភេរវកម្ម ហើយមានសមាសភាព:

-ក្រុមវិភាគរួមមាន:

១- ឯកឧត្តម **ប្រាក់ សុខុន** ទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី - រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក គជបភ .......................................................................................សមាជិក

២- ឧត្តមសេនីយ៍ឯក **ម៉ល់ រឿម** ទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី - នាយករងសេនាធិការចំរុះ និងជានាយកស្រាវជ្រាវចារកិច្ចអគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ ...................................សមាជិក



ហ

៣- ឧត្តមសេនីយ៍ឯក យូ ស៊ុនឡុង ទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី-អគ្គស្នងការរងនគរបាលជាតិ.សមាជិក

៤- ឯកឧត្តម អ៊ុច បូរិទ្ធិ រដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ .............សមាជិក

៥- ឧត្តមសេនីយ៍ឯក សៅ សុខា មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស-សមាជិក គជបភ ......សមាជិក

៦- ឧត្តមសេនីយ៍ឯក នេត្រ សាវឿន អគ្គស្នងការរងនគរបាលជាតិ ..............................សមាជិក

៧- ឧត្តមសេនីយ៍ឯក សុខ ផល អគ្គស្នងការរងនគរបាលជាតិ ......................................សមាជិក

៨ - ឧត្តមសេនីយ៍ឯក ជុំ ហាក់ មេបញ្ជាការរង កងទ័ពជើងគោក ...................................សមាជិក

៩ - ឯកឧត្តម ហេង ពៅ ទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី - ស្នងការនគរបាលក្រុងភ្នំពេញ ........សមាជិក

១០ - ឧត្តមសេនីយ៍ឯក គន្ធ សំអឿន ប្រធាននាយកដ្ឋានកណ្តាលសន្តិសុខ .........................សមាជិក

១១- ឧត្តមសេនីយ៍ត្រី ស៊ិន សុផាន្នី នាយសេនាធិការរង និងជានាយការិយាល័យកណ្តាលស្រាវជ្រាវកងរាជអាវុធហត្ថលើផ្ទៃប្រទេស ............................................................................សមាជិក

១២- ឧត្តមសេនីយ៍ត្រី យ៉ៅ គីមអ៊ី មេបញ្ជាការកងរាជអាវុធហត្ថក្រុងភ្នំពេញ ..........................សមាជិក

-ក្រុមចារកម្មរួមមាន:

១- ឧត្តមសេនីយ៍ឯក គន្ធ សំអឿន ប្រធាននាយកដ្ឋានកណ្តាលសន្តិសុខ ............................សមាជិក

២- ឧត្តមសេនីយ៍ទោ មឹត គីមហុង ប្រធាននាយកដ្ឋានប្រឆាំងភេរវកម្ម ..............................សមាជិក

៣- ឧត្តមសេនីយ៍ទោ សំរិត ហ៊ុន នាយការិយាល័យទី ២ កងទ័ពជើងគោក .........................សមាជិក

៤- ឧត្តមសេនីយ៍ត្រី ស៊ិន សុផាន្នី នាយសេនាធិការរង និងជានាយការិយាល័យកណ្តាលស្រាវជ្រាវកងរាជអាវុធហត្ថលើផ្ទៃប្រទេស ..................................................................................សមាជិក

៥- ឧត្តមសេនីយ៍ត្រី ឆែ ស៊ីណារិទ្ធ ប្រធាននាយកដ្ឋានព័ត៌មានទូទៅ ................................សមាជិក

៦- ឧត្តមសេនីយ៍ត្រី គៀត ច័ន្ទថារិទ្ធ ប្រធាននាយកដ្ឋានជនបរទេស ...............................សមាជិក

៧- ឧត្តមសេនីយ៍ត្រី មាស អ៊ាន នាយរងនាយកដ្ឋានស្រាវជ្រាវចារកិច្ច អគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ ..................................................................................................សមាជិក

៨- ឧត្តមសេនីយ៍ត្រី សិទ្ធិ សារឿន នាយរងនាយកដ្ឋានស្រាវជ្រាវចារកិច្ច អគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ ...........................................................................................សមាជិក

៩- ឧត្តមសេនីយ៍ត្រី គីម នាន ជំនួយការសម្តេចនាយករដ្ឋមន្ត្រី ...................................សមាជិក

១០- វរសេនីយ៍ឯក ហ៊ី វុទ្ធ ស្នងការរងនគរបាលក្រុងភ្នំពេញ .........................................សមាជិក

១១- វរនារីឯក មី ឌីណា នាយការិយាល័យទី ២ កងទ័ពជើងទឹក .....................................សមាជិក

១២-វរសេនីយ៍ឯក ពៅ ពិចិត្រ នាយក្រុមប្រតិបត្តិការក្នុងប្រទេសនាយកដ្ឋានស្រាវជ្រាវចារកិច្ចអគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ ..........................................................................សមាជិក

១៣-វរសេនីយ៍ឯក ស៊ឹម ហុង មេបញ្ជាការរងកងរាជអាវុធហត្ថក្រុងភ្នំពេញ ..........................សមាជិក



ﾘ

១៤-វរៈសេនិយត្រី ម៉ាក់ សុជាវី សមាជិកក្រុមលេខាសម្តេចនាយករដ្ឋមន្ត្រី .........................សមាជិក

**ប្រការ៨:** មន្ត្រី បុគ្គលិកបំរើការក្នុងលេខាធិការដ្ឋាន សុទ្ធតែជាអ្នកដែលមានក្របខ័ណ្ឌស្រាប់ លើកលែងតែមានតំរូវការអ្នកជំនាញដូចជាកុំព្យូទ័រ ឬជំនាញផ្សេងៗ ទើបអនុញ្ញាតស្នើសុំក្របខ័ណ្ឌថ្មី ដោយបញ្ចូលមកក្នុងក្របខ័ណ្ឌទីស្តីការគណៈរដ្ឋមន្ត្រី ។

**ប្រការ៩:** លេខាធិការដ្ឋាន គជបភ មានត្រា និងថវិកាដោយឡែករបស់ខ្លួន ។ ក្នុងពេលថវិកាដោយឡែករបស់លេខាធិការដ្ឋាន គជបភ មិនទាន់បានទទួលការអនុម័ត រាល់ចំណាយដំណើរការនៃលេខាធិការដ្ឋាន គជបភ ជាបន្ទុករបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

ទីស្តីការគណៈរដ្ឋមន្ត្រី និងក្រសួងមហាផ្ទៃមានភារកិច្ចរៀបចំអគារសំរាប់ធ្វើជាលេខាធិការដ្ឋាន និងសំរាប់ធ្វើជាមូលដ្ឋាននានារបស់លេខាធិការដ្ឋាន ។

**ប្រការ ១០:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រី ប្រធានស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដែលមានឈ្មោះនៅក្នុងប្រការ ៤ - ប្រការ ៦ និងប្រការ ៧ ត្រូវអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាព ចាប់តាំងពីថ្ងៃចុះហត្ថលេខានេះ តទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងការពារជាតិ
- ក្រសួងមហាផ្ទៃ
- អគ្គលេខាធិការដ្ឋានរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច និងឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ១០
- កាលប្បវត្តិ - ឯកសារ